ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

ឿងព្រហ្មទណ្ឌ

ខ : ៦៦៣

៧-០៧-២០១៤

ាលដីកា

៣ ក្រIV "វ"

៨-០៩-២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ : នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤ ដោយមាន ៖

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

### ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ : ៦៦៣ ចុះថ្ងៃទី១៧-០៧-២០១៤ ដែលមាន ៖

១- ជនជាប់ចោទឈ្មោះ [redacted] ជិងយាន (ប្តឹងឧទ្ធរណ៍) ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិចិន កាន់លិខិតឆ្លងដែនលេខ ២១៥១៧៥៨២០ ចុះថ្ងៃទី១៣-០៤-២០០៧ ទីលំនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ជានីតិជន ។ (ក្រៅឃុំ)

- មានលោក [redacted] ពៅស៊ាង, លោកស្រី [redacted] សុគន្ធា និងលោក [redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

២- ជនជាប់ចោទឈ្មោះ [redacted] គួសុង (ប្តឹងឧទ្ធរណ៍) ភេទប្រុស អាយុ៦៧ឆ្នាំ ជាតិចិន កាន់លិខិតឆ្លងដែនលេខ ២១៥១៨២៧៤៧ ចុះថ្ងៃទី១៦-០៤-២០០៧ ទីលំនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ជានីតិជន ។ (ក្រៅឃុំ)

- មានលោក [redacted] ពៅស៊ាង, លោកស្រី [redacted] សុគន្ធា និងលោក [redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៣- ជនជាប់ចោទឈ្មោះ [redacted] ទើរអ៊ួយ (ប្តឹងឧទ្ធរណ៍) ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិចិន កាន់លិខិតឆ្លងដែនលេខ ២០០២១៧៣១ ចុះថ្ងៃទី១០-១២-២០០២ ទីលំនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ជានីតិជន ។ (ក្រៅឃុំ)

- មានលោក [redacted] ពៅស៊ាង, លោកស្រី [redacted] សុគន្ធា និងលោក [redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៤- ជនជាប់ចោទឈ្មោះ [redacted] យូវលាង (ប្តឹងឧទ្ធរណ៍) ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិចិន កាន់លិខិតឆ្លងដែនលេខ ២១៤៨២៤៩៥៤ ចុះថ្ងៃទី០៨-១២-២០០៦ ទីលំនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ជានីតិជន ។ (ក្រៅឃុំ)

- មានលោក [redacted] ពៅស៊ាង, លោកស្រី [redacted] សុគន្ធា និងលោក [redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៥- ជនជាប់ចោទឈ្មោះ [redacted] ម៉ឹងឆោ (ប្តឹងឧទ្ធរណ៍) ភេទប្រុស អាយុ៦៥ឆ្នាំ ជាតិចិន កាន់លិខិតឆ្លងដែនលេខ ១៣១១៧៩១៨៨ ចុះថ្ងៃទី១៨-០១-២០០១ ទីលំនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ជានីតិជន ។ (ក្រៅឃុំ)

- មានលោក [redacted] ពៅស៊ាង, លោកស្រី [redacted] សុគន្ធា និងលោក [redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៦- ជនជាប់ចោទឈ្មោះ [redacted] ឆុងហៃ្វ (ប្តឹងឧទ្ធរណ៍) ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិចិន កាន់លិខិតឆ្លងដែនលេខ ២១២៤០១៩៥៥ ចុះថ្ងៃទី១៩-០៤-២០០៥ ទីលំនៅផ្ទះលេខ [redacted]

៤៥២

[redacted] ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ជានីតិជន ។ (ក្រៅឃុំ)

- មានលោក [redacted] ពៅស៊ាង, លោកស្រី [redacted] សុគន្ធា និងលោក [redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៧- ជនជាប់ចោទឈ្មោះ [redacted] ស៊ីនជួរ (ប្ដឹងឧទ្ធរណ៍) ភេទប្រុស អាយុ៧៩ឆ្នាំ ជាតិចិន កាន់លិខិតឆ្លងដែនលេខ ២១៣២០៦៣៨៤ ចុះថ្ងៃទី០៤-១០-២០០៥ ទីលំនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ជានីតិជន ។ (ក្រៅឃុំ)

- មានលោក [redacted] ពៅស៊ាង, លោកស្រី [redacted] សុគន្ធា និងលោក [redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៨- ជនជាប់ចោទឈ្មោះ [redacted] ជីនស៊ីន (ប្ដឹងឧទ្ធរណ៍) ភេទប្រុស អាយុ៦៥ឆ្នាំ ជាតិចិន កាន់លិខិតឆ្លងដែនលេខ ១៣១៣៩៧៨៣២ ចុះថ្ងៃទី១៥-០៣-២០០១ ទីលំនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ជានីតិជន ។ (ក្រៅឃុំ)

- មានលោក [redacted] ពៅស៊ាង, លោកស្រី [redacted] សុគន្ធា និងលោក [redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ជាប់ចោទពីបទ: ប្រើប្រាស់លិខិតសាធារណៈក្លែង (អត្តសញ្ញាណប័ណ្ណ), បទ ឆបោក និងបទប្ដឹងបរិហារបង្កាច់កេរ្ដិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១០ និងឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា៦៣០ មាត្រា៣៧៧ មាត្រា៣៧៨ មាត្រា៣១១ និងមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ។

៩- ជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង (ប្ដឹងឧទ្ធរណ៍) ភេទស្រី អាយុ៥៧ឆ្នាំ ជាតិចិន ទីកន្លែងកំណើតក្រុង [redacted] ទីលំនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្ដីឈ្មោះ [redacted] "រ" ជានីតិជន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ: បទប្ដឹងបរិហារបង្កាច់កេរ្ដិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១០, ២០១១ និងឆ្នាំ២០១២ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា៣១១ និងមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ។

ជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណី :

- ឈ្មោះ [redacted] ឆឹងសួយ ភេទប្រុស អាយុ៦៣ឆ្នាំ ជាតិចិន ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted]

- ឈ្មោះ [redacted] ម៉ី ភេទស្រី អាយុ៥៨ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] ។

មានលោក [redacted] ទ្រី, លោក [redacted] ឆាយ, លោក [redacted] ធារ៉ា និងលោក [redacted] សុជាតិ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ។

ឯរឿងហេតុមានដូចតទៅ ៖

តាមពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] ឆឹងសួយ ភេទប្រុស អាយុ៦៣ឆ្នាំ និងឈ្មោះ [redacted] ម៉ី ភេទស្រី អាយុ៥៨ឆ្នាំ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ថាឈ្មោះ [redacted] ជឹងយាន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វួយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ្វៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន ជាជនជាតិតៃវ៉ាន់ បានប្រើឧបាយកលទុច្ចរិតឱ្យជនរងគ្រោះឈ្មោះ [redacted] ឆឹងសួយ និងឈ្មោះ [redacted] ម៉ី ដើរជួយរកទិញដីឱ្យ ដោយមានការទុកចិត្តជនរងគ្រោះទាំងពីរនាក់ ក៏បានជួយចេញប្រាក់មុន ដើម្បីទិញដីស្ថិតនៅភូមិគោកស្ដៅ ភូមិត្រពាំងក្រពើ ឃុំទឹកហូត ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង ហើយអ្នកទាំងប្រាំបីនាក់ បានកក់ប្រាក់មុន ៣០% នៃតម្លៃដីសរុប ហើយនឹងប្រគល់ប្រាក់ថ្លៃទិញដីមកឱ្យគ្រប់ចំនួននៅពេលដែលផ្ទេរកម្មសិទ្ធិរួច ។ ពេលនោះអ្នកទាំងប្រាំបីនាក់ បានប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្លែង ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិលើដីទាំងនោះមកជាកម្មសិទ្ធិរបស់ខ្លួន តែពេលដែលផ្ទេរកម្មសិទ្ធិដាក់ឈ្មោះអ្នកទាំងប្រាំបីនាក់រួចរាល់ហើយ អ្នកទាំងប្រាំបីនាក់បានគេចខ្លួនទាំងអស់គ្នា ដោយពុំព្រមប្រគល់ប្រាក់បន្ថែមគ្រប់ចំនួនឡើយ ។ លុះក្រោយមកជនរងគ្រោះ បានជួបអ្នកទាំងប្រាំបីនាក់ខាងលើ ហើយអ្នកទាំងប្រាំបីនាក់នេះបានសន្យាថានឹងប្រគល់ឯកសារដីមកឱ្យជនរងគ្រោះវិញ និងសុខចិត្តផ្ដិតមេដៃផ្ទេរកម្មសិទ្ធិនៅមុខមន្ត្រីសុរិយោដីឱ្យទៅអ្នកទិញពីជនរងគ្រោះឈ្មោះ [redacted] គួយអ៊ឹង ដោយអ្នកទាំងប្រាំបីនាក់ឱ្យជនរងគ្រោះប្រគល់ប្រាក់ចំនួន ៣០% វិញ ។ ដោយមានការទុកចិត្ត និងការអង្វរលួងលោម ជនរងគ្រោះប្រគល់ប្រាក់ឱ្យអ្នកទាំងប្រាំបីនាក់ ក្នុងម្នាក់ៗចំនួន ២៥,០០០ដុល្លារអាមេរិក ហើយអ្នកទាំងប្រាំបីនាក់សន្យាថានឹងមិនទាមទារដីនេះវិញឡើយ និងសុខចិត្តបំពេញគ្រប់នីតិវិធីប្រគល់ដីនេះមកឱ្យជនរងគ្រោះវិញ ។ តែអ្នកទាំងប្រាំបីនាក់ ពុំបានប្រគល់ដីទាំងអស់មកឱ្យជនរងគ្រោះតាមការសន្យាវិញឡើយ ហើយថែមទាំងប្ដឹងជនរងគ្រោះពីបទឆបោក និងបទរំលោភលើទំនុកចិត្ត និងបទលួចលក់អចលនវត្ថុជាច្រើនលើកច្រើនសារក្នុងឆ្នាំ២០១០ ឆ្នាំ២០១១ តែត្រូវបានតុលាការតម្កល់រឿងទុកឥតចាត់ការរហូត ។

ក្រោយពេលមានការព្រមព្រៀងពីឈ្មោះ [redacted] ជឹងយាន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វួយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ្វៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន ប្រគល់ដីឱ្យជនរងគ្រោះរួចមក ឈ្មោះ [redacted] ម៉ី ក៏បានលក់ដីនោះ ឱ្យទៅឈ្មោះ [redacted] គួយអ៊ឹង តាមផ្លូវច្បាប់ ដោយ

បានព្រមព្រៀងធ្វើការផ្ទេរកម្មសិទ្ធិពីឈ្មោះអ្នកទាំងប្រាំបីនាក់ ឲ្យឈ្មោះ [redacted] គួយអ៊ីង ប៉ុន្តែអ្នកទាំងប្រាំបីនាក់ខាងលើ ពុំបានចូលខ្លួនមកបំពេញបែបបទនៅមន្ត្រីសុរិយោដី ទើបខកខាននៅក្នុងការផ្ទេរកម្មសិទ្ធិ ។ ស្រាប់តែនៅឆ្នាំ២០១០ ឆ្នាំ២០១១ និងឆ្នាំ២០១២ រហូតមកឈ្មោះ [redacted] គួយអ៊ីង បែរជាប្ដឹងជនរងគ្រោះជាច្រើនលើក ពីបទសមគំនិតឆបោក និងបទរំលោភលើទំនុកចិត្ត តែត្រូវបានតុលាការតម្កល់រឿងទុកឥតចាត់ការរហូត ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៧១ "ទ" ចុះថ្ងៃទី០២-១២-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្ដីមានខ្លឹមសារថា :

១- ផ្ដន្ទាទោស :

ក. ឈ្មោះ [redacted] ជិន ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិចិន

ខ. ឈ្មោះ [redacted] គួសុង ភេទប្រុស អាយុ៦៧ឆ្នាំ ជាតិចិន

គ. ឈ្មោះ [redacted] ទើអ៊ួយ ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិចិន

ឃ. ឈ្មោះ [redacted] យូវលាង ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិចិន

ង. ឈ្មោះ [redacted] ម៉ឹងឆោ ភេទប្រុស អាយុ៦៥ឆ្នាំ ជាតិចិន

ច. ឈ្មោះ [redacted] ឆុងហ៊ៃ ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិចិន

ឆ. ឈ្មោះ [redacted] ស៊ីនធួរ ភេទប្រុស អាយុ៧៩ឆ្នាំ ជាតិចិន

ជ. ឈ្មោះ [redacted] ជីនស៊ីន ភេទប្រុស អាយុ៦៥ឆ្នាំ ជាតិចិន

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៥,០០០,០០០ (ប្រាំលាន) រៀល ពីបទ ប្រើប្រាស់លិខិតសាធារណៈក្លែង (អត្តសញ្ញាណប័ណ្ណ) បទ ឆបោក និងបទបរិហារបង្កាច់កេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១០ និងឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ៦៣០ មាត្រា៣៧៧ មាត្រា៣៧៨ មាត្រា៣១១ និងមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ។

២- ផ្ដន្ទាទោសឈ្មោះ [redacted] គួយអ៊ីង ភេទស្រី អាយុ៥៧ឆ្នាំ ជាតិចិន ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ១,០០០,០០០ (មួយលាន) រៀល ពីបទ បរិហារបង្កាច់កេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១០ ឆ្នាំ២០១១ និងឆ្នាំ២០១២ តាមបញ្ញត្តិ មាត្រា៣១១ និងមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ។

៣- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ជិន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ៊ួយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ៊ៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន រួមគ្នាសងសំណងថ្លៃខូចខាត ចំនួន ៤០០,០០០ (បួនសែន)ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ២០,០០០ (ពីរម៉ឺន)ដុល្លារ

អាមេរិក ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឈ្មោះ [redacted] ការទាមទារលើសពីនេះត្រូវច្រានចោល ។

៤- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង សងសំណងជម្ងឺចិត្តចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ឹងស្វួយ និងឈ្មោះ [redacted] ម៉ី ការទាមទារលើសពីនេះ ត្រូវច្រានចោល ។

៥- ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ជិន ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិចិន ឈ្មោះ [redacted] គួសុង ភេទប្រុស អាយុ៦៧ឆ្នាំ ជាតិចិន ឈ្មោះ [redacted] ទើអ្វួយ ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិចិន ឈ្មោះ [redacted] យូវលាង ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិចិន ឈ្មោះ [redacted] ម៉ឹងឆោ ភេទប្រុស អាយុ៦៥ឆ្នាំ ជាតិចិន ឈ្មោះ [redacted] ផុងហ្វៃ ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិចិន ឈ្មោះ [redacted] ស៊ីនធួរ ភេទប្រុស អាយុ៧៩ឆ្នាំ ជាតិចិន ឈ្មោះ [redacted] ជីនស៊ីន ភេទប្រុស អាយុ៦៥ឆ្នាំ ជាតិចិន យកមកទទួលទោសតាមអំណាចនៃសាលក្រមព្រហ្មទណ្ឌនេះ ដោយអនុវត្តតាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី១៣-១១-២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០២-១២-២០១៣ កំបាំងមុខតែត្រូវចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជីងយាន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វួយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ផុងហ្វៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន ឈ្មោះ [redacted] គួយអ៊ីង មេធាវីការពារសិទ្ធិជនជាប់ចោទលោក [redacted] ធារី និងលោក [redacted] ស៊ីណាល់ និងចំពោះមុខលោក[redacted] ទ្រី ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ឹងស្វួយ និងឈ្មោះ [redacted] ម៉ី ។

បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-០១-២០១៤ របស់លោកមេធាវី [redacted] ស៊ីណាល់ ទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ទ" ចុះថ្ងៃទី០២-១២-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី២ និងទី៤ នៃសេចក្តីសម្រេច ។

បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣-០១-២០១៤ របស់លោកមេធាវី [redacted] ធារី ទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីជនជាប់ចោទឈ្មោះ [redacted] ផុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វួយ, [redacted] យូវលាង, [redacted] ម៉ឹងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ទ" ចុះថ្ងៃទី ០២-១២-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី០៤-០៨-២០១៤ ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៤-០៩-២០១៤ ។

នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី

- អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង នៅចៅក្រមស៊ើបសួរថា ៖ ខ្លួនពិតជាបានដាក់ពាក្យបណ្តឹងលើឈ្មោះ [redacted] ឆឹងសួយ និងឈ្មោះ [redacted] ម៉ី មែន នៅសាលាដំបូងខេត្តកំពង់ឆ្នាំង និងសាលាដំបូងរាជធានីភ្នំពេញមែន ពីបទឆបោក ។ ខ្លួនមិនបានទទួលដំណឹងថា ការប្តឹងរបស់ខ្លួនលើឈ្មោះ [redacted] ម៉ី នៅតុលាការខេត្តកំពង់ឆ្នាំង និងតុលាការក្រុងភ្នំពេញ ត្រូវបានតុលាការចេញដីកាតម្កល់រឿងទុកឥតចាត់ការនោះទេ រីឯសេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ក៏ខ្លួនមិនបានដឹងដែរ ។

- លោកមេធាវី [redacted] ពៅស៊ាង ការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីរបស់ខ្លួនបានទទួលដំណឹងអំពីសវនាការជំនុំជម្រះរបស់សាលាឧទ្ធរណ៍នេះហើយ ។ មូលហេតុដែលកូនក្តីខ្លួនទាំង៨នាក់ ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ព្រោះការចោទប្រកាន់លើកូនក្តីខ្លួនពីបទ ឆបោក បទ ប្តឹងបរិហារបង្កាច់កេរ្តិ៍ បទ ប្រើប្រាស់លិខិតសាធារណៈក្លែង គឺជាការមិនត្រឹមត្រូវ ។ ចំពោះការចោទប្រកាន់ពីបទឆបោក គឺពុំមានការឆបោកទេ កូនក្តីខ្លួនពុំដែលមានចេតនាឆបោកលើដើមបណ្តឹងរដ្ឋប្បវេណី ព្រោះកូនក្តីខ្លួនជាជនជាតិចិន ហើយពុំចេះអក្សរខ្មែរទេ ហើយចំពោះការចោទប្រកាន់ពីបទបរិហាបង្កាច់កេរ្តិ៍ និងបទ ប្រើប្រាស់លិខិតសាធារណៈក្លែងនោះ ការដាក់ពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហួសអាជ្ញាយុកាលនៃបទល្មើសហើយ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ កូនក្តីរបស់ខ្លួនទាំង៨នាក់ បានប្រគល់ប័ណ្ណឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីអស់ហើយ ប៉ុន្តែមិនទាន់ទទួលបានប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណីទេ ហើយការផ្តិតមេដៃលើលិខិតលក់ផ្តាច់ គឺជាក្លែងបន្លំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបោកប្រាស់កូនក្តីខ្លួនថា ឲ្យផ្តិតមេដៃលើលិខិតសុំប្តូរប័ណ្ណជាលក្ខណៈប្រព័ន្ធ ។ ចំពោះការចោទប្រកាន់កូនក្តីខ្លួនពីបទប្តឹងបរិហារបង្កាច់កេរ្តិ៍ គឺជាការមិនត្រឹមត្រូវ ដោយហេតុថា ការដាក់ពាក្យបណ្តឹងរបស់កូនក្តីខ្លួនចំពោះដើមបណ្តឹងរដ្ឋប្បវេណី [redacted] ឆឹងសួយ និង [redacted] ម៉ី ទោះបីត្រូវបានតម្កល់រឿងទុកឥតចាត់ការ ក្នុងរឿងព្រហ្មទណ្ឌ ប៉ុន្តែក្នុងសំអាងហេតុនេះដីកាសម្រេចតម្កល់រឿងទុកមិនចាត់ការនោះ បញ្ជាក់ច្បាស់ណាស់ថា គឺជារឿងរដ្ឋប្បវេណី ដូចនេះការប្តឹងរបស់កូនក្តីខ្លួនមានអង្គហេតុត្រឹមត្រូវ ដែលមិនមែនជាការប្តឹងបរិហារបង្កាច់កេរ្តិ៍នោះទេ ម្យ៉ាងទៀតបើគិតពីអាជ្ញាយុកាលនៃបទល្មើសប្តឹងបរិហារបង្កាច់កេរ្តិ៍នេះ ក៏បានហួសទៅហើយ តាមមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ។ រីឯការចោទប្រកាន់កូនក្តីខ្លួនពីបទល្មើសប្រើប្រាស់លិខិតសាធារណៈក្លែង ក៏ពុំមានលក្ខណៈត្រឹមត្រូវដែរ ព្រោះអាជ្ញាយុកាលនៃបទល្មើសត្រូវបានផុតហើយ តាមមាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រោះកូនក្តីខ្លួនប្រើប្រាស់ប័ណ្ណតាំងពីឆ្នាំ១៩៩៧ ដើម្បីទិញដី ម្យ៉ាងទៀតកូនក្តីខ្លួនក៏ពុំបានដឹងថា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន ជាប័ណ្ណក្លែងដែរ ដូចនេះកូនក្តីខ្លួនពុំមានចេតនាក្នុងការប្រើប្រាស់លិខិតក្លែង ។ កូនក្តីខ្លួនមិនមានចេតនាប្រើប្រាស់លិខិតសាធារណៈក្លែង ព្រោះកូនក្តីខ្លួនមិនបានដឹងថាអត្តសញ្ញាណប័ណ្ណនោះក្លែងក្លាយ ។ ក្នុងរឿងក្តីនេះ គ្មានកិច្ចសន្យាទិញលក់ដីទេ ហើយក៏គ្មានការប្រគល់ប្រាក់ឲ្យកូនក្តីខ្លួនដែរ ការផ្តិតមេដៃ គឺជាការបោកប្រាក់កូនក្តីខ្លួន ។ អាជ្ញាយុកាលនៃបទល្មើស បានហួសហើយ ។ ហេតុនេះ

សំណូមពរសុំឱ្យសាលាឧទ្ធរណ៍សម្រេចបដិសេធសាលក្រមរបស់សាលាដំបូងចោលជាអសារបង់ និងសុំបដិសេធដីកាបង្គាប់ឱ្យចាប់ខ្លួន កូនក្តីខ្លួន ។

- លោកមេធាវី [redacted] ទ្រី ការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា : កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ឆឹងស្វយ និងឈ្មោះ [redacted] ម៉ី បានទទួលដីកាកោះរួចហើយ ។ ក្នុងរឿងនេះ ការសម្រេចសេចក្តីរបស់សាលាដំបូង មានលក្ខណៈត្រឹមត្រូវហើយ ដោយហេតុថា : ជនជាប់ចោទជាជនជាតិចិន ទាំង៨នាក់ដែលមានឈ្មោះ [redacted] ឆុងហៃ, [redacted] ជីនស៊ីន, [redacted] ជឹងយាន, [redacted] គួសុង, [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ុងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ពិតជាបានមកពឹងពាក់កូនក្តីខ្លួន ឱ្យដើររកទិញដីឱ្យប្រាកដមែន ហើយអ្នកទាំងប្រាំបីនាក់ បានកក់ប្រាក់មុន ៣០% នៃតម្លៃដីសរុប ហើយនឹងប្រគល់ប្រាក់ថ្លៃទិញដីមកឱ្យគ្រប់ចំនួននៅពេលដែលផ្ទេរកម្មសិទ្ធិរួច ។ ក្រោយពេលដែលផ្ទេរកម្មសិទ្ធិដាក់ឈ្មោះអ្នកទាំងប្រាំបីនាក់រួចរាល់ហើយ ជនជាប់ចោទបានគេចខ្លួនទាំងអស់គ្នា ដោយពុំព្រមប្រគល់ប្រាក់បន្ថែមគ្រប់ចំនួនឡើយ ។ ក្រោយមកកូនក្តីខ្លួន បានជួបជនជាប់ចោទទាំង៨នាក់ខាងលើ ដោយជនជាប់ចោទបានសន្យាថានឹងប្រគល់ឯកសារដីមកឱ្យកូនក្តីខ្លួនវិញ និងសុខចិត្តផ្តិតមេដៃផ្ទេរកម្មសិទ្ធិនៅមុខមន្ត្រីសុរិយោដីឱ្យទៅអ្នកទិញឈ្មោះ [redacted] គួយអ៊ីង ដោយអ្នកទាំងប្រាំបីនាក់ឱ្យជនរងគ្រោះប្រគល់ប្រាក់ចំនួន ៣០% វិញ ។ កូនក្តីខ្លួនបានប្រគល់ប្រាក់ឱ្យទៅជនជាប់ចោទរួចហើយ ប៉ុន្តែជនជាប់ចោទមិនដែលមកផ្តិតមេដៃផ្ទេរកម្មសិទ្ធិដីឱ្យទៅឈ្មោះ [redacted] គួយអ៊ីងទេ ថែមទាំងដាក់ពាក្យបណ្តឹងមកលើកូនក្តីខ្លួន ពីបទ ឆបោក ហើយដែលត្រូវបានអយ្យការអមសាលាដំបូងក៏ដូចជាមហាអយ្យការអមសាលាឧទ្ធរណ៍ សម្រេចតម្កល់រឿងទុកឥតចាត់ការហើយ ។ ការប្តឹងមកលើកូនក្តីខ្លួន ដោយជនជាប់ចោទ ពុំមែនកើតឡើងតែម្តងទេ គឺចំនួន ៧ដងមកហើយ នៅចំពោះមុខតុលាការភ្នំពេញ, តុលាការកំពង់ឆ្នាំង និងក្រសួងមហាផ្ទៃផង ។ ចំពោះការក្លែងអត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ គឺជនជាប់ចោទបានយកមកប្រើប្រាស់ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិដីទៅវិញទៅមក សព្វថ្ងៃកូនក្តីខ្លួនបានទុកប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងអត្តសញ្ញាណប័ណ្ណក្លែងសញ្ជាតិខ្មែរ របស់ជនជាប់ចោទទាំងប្រាំបីនាក់នេះ ។ ការផ្តិតមេដៃនៅចំពោះមុខសុរិយោដី ដូចមានក្នុងរូបថត ព្រមទាំងមានការបញ្ជាក់របស់មន្ត្រីសុរិយោដីផងនោះ គឺជាការផ្តិតមេដៃលើលិខិតលក់ផ្តាច់ មិនមែនជាការផ្តិតមេដៃលើការសុំប្តូរប័ណ្ណនោះទេ នៅពេលផ្តិតមេដៃនោះគឺមានអ្នកបកប្រែត្រឹមត្រូវ ដែលជនជាប់ចោទបានដឹងច្បាស់ថា ផ្តិតមេដៃដើម្បីអ្វី ប៉ុន្តែជនជាប់ចោទនៅតែមិនបានប្រគល់ដីមកឱ្យកូនក្តីខ្លួនទេ រហូតមកដល់សព្វថ្ងៃនេះ ការផ្ទេរកម្មសិទ្ធិដីនៅមិនទាន់បានចប់នៅឡើយ ។ ការសម្រេចសេចក្តីរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវហើយ សុំឱ្យសាលាឧទ្ធរណ៍សម្រេចតម្កល់ទុកជាបានការដដែល ។

- តំណាងមហាអយ្យការសន្និដ្ឋានថា : ចំពោះការចោទប្រកាន់ពីបទ ប្តឹងបរិហារបង្កាច់កេរ្តិ៍ និងបទប្រើប្រាស់លិខិតក្លែងមានលក្ខណៈត្រឹមត្រូវ សុំសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការ រីឯការចោទប្រកាន់ពីបទ ឆបោក សុំសភាព្រហ្មទណ្ឌ ពិនិត្យ និងពិចារណាតាមច្បាប់ ។

- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ [redacted] គួយអ៊ីង

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

- ក្រោយពីបានពិចារណាលើគ្រប់ភស្តុតាង និងឯកសារផ្សេងៗ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

យល់ឃើញថា

១- ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-០១-២០១៤ របស់លោកមេធាវី [redacted] ស៊ីណាល់ ទទួលសិទ្ធិប្ដឹងឧទ្ធរណ៍ពីជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ទ" ចុះថ្ងៃទី០២-១២-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី២ និងទី៤ នៃសេចក្ដីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

- ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣-០១-២០១៤ របស់លោកមេធាវី [redacted] ធារី ទទួលសិទ្ធិប្ដឹងឧទ្ធរណ៍ពីជនជាប់ចោទឈ្មោះ [redacted] អុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើវអ៊ួយ, [redacted] យូវលាង, [redacted] ម៉ឺងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ទ" ចុះថ្ងៃទី០២-១២-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្ដីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២- លោក [redacted] ពៅស៊ាង មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អុងហ្វៃ, [redacted] ជិនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើវអ៊ួយ, [redacted] យូវលាង, [redacted] ម៉ឺងឆោ និងឈ្មោះ [redacted] ស៊ីនធួរ បានបញ្ជាក់ថា កូនក្ដីរបស់ខ្លួនបានទទួលដំណឹងអំពីសវនាការជំនុំជម្រះរបស់សាលាឧទ្ធរណ៍នេះហើយ ។ រីឯលោក ណាច ទ្រី មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានបញ្ជាក់ថា កូនក្ដីរបស់ខ្លួន ឈ្មោះ [redacted] អ៊ឹងស្វយ និងឈ្មោះ [redacted] ម៉ី បានទទួលដីកាកោះរួចហើយដែរ ។ ហេតុនេះ ក្រុមប្រឹក្សាបន្តនីតិវិធីពិភាក្សាដេញដោលដោយចាត់ទុកជាចំពោះមុខ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង មិនមានវត្តមាននាពេលសវនាការដោយគ្មានមូលហេតុ និងគ្មានមេធាវីការពារសិទ្ធិ ក្រុមប្រឹក្សាបន្តនីតិវិធីពិភាក្សាដេញដោល ដោយកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង ។

៣- លោក [redacted] ពៅស៊ាង មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើវអ៊ួយ, [redacted] យូវលាង, [redacted] ម៉ឺងឆោ និងឈ្មោះ [redacted] ស៊ីនធួរ បានបញ្ជាក់

ថា កូនក្តីខ្លួនទាំង៨នាក់ ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ព្រោះការចោទប្រកាន់លើកូនក្តីខ្លួនពីបទ ឆបោក បទប្តឹងបរិហាបង្កាច់កេរ្តិ៍ បទ ប្រើប្រាស់លិខិតសាធារណៈក្លែង គឺជាការមិនត្រឹមត្រូវ ។ ចំពោះការចោទប្រកាន់ពីបទឆបោក គឺពុំមានការឆបោកទេ កូនក្តីខ្លួនពុំដែលមានចេតនាឆបោកលើដើមបណ្តឹងរដ្ឋប្បវេណី ព្រោះកូនក្តីខ្លួនជាជនជាតិចិន ហើយពុំចេះអក្សរខ្មែរទេ ហើយចំពោះការចោទប្រកាន់ពីបទបរិហាបង្កាច់កេរ្តិ៍ និងបទប្រើប្រាស់លិខិតសាធារណៈក្លែងនោះ ការដាក់ពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហួសអាជ្ញាយុកាលនៃបទល្មើសហើយ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

ក្រុមប្រឹក្សាយល់ថា : ការលើកឡើងរបស់លោកមេធាវី [redacted] ពៅស៊ាង មានលក្ខណៈត្រឹមត្រូវខ្លះចំពោះបទល្មើស ឆបោក និងបទ ប្តឹងបរិហាបង្កាច់កេរ្តិ៍ និងមិនត្រឹមត្រូវខ្លះ ចំពោះ បទ ប្រើប្រាស់លិខិតសាធារណៈក្លែង ដោយហេតុថា :

- ចំពោះបទល្មើសឆបោក : តាមការលើកឡើងរបស់លោកមេធាវី [redacted] ពៅស៊ាង នាពេលសវនាការសាលាឧទ្ធរណ៍ថា កូនក្តីរបស់ខ្លួនទាំង៨នាក់ បានប្រគល់ប័ណ្ណឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីអស់ហើយ ប៉ុន្តែមិនទាន់ទទួលបានប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណីទេ ហើយការផ្តិតមេដៃលើលិខិតលក់ផ្តាច់ គឺជាការក្លែងបន្លំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបោកប្រាស់កូនក្តីខ្លួនថា ឱ្យផ្តិតមេដៃលើលិខិតសុំប្តូរប័ណ្ណជាលក្ខណៈប្រព័ន្ធ ។ ក្រុមប្រឹក្សាយល់ថា : ការលើកឡើងរបស់លោកមេធាវី [redacted] ពៅស៊ាង ថា កូនក្តីខ្លួនបានប្រគល់ប័ណ្ណទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីរួចហើយនោះ គឺស្របគ្នានឹងការទទួលស្គាល់របស់លោក [redacted] ទ្រី មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីថា សព្វថ្ងៃកូនក្តីខ្លួនបានទុកប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងអត្តសញ្ញាណប័ណ្ណក្លែងសញ្ជាតិខ្មែរ របស់ឈ្មោះ [redacted] អុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ុងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ដែលជនជាប់ចោទទាំងអស់ បានប្រគល់ឱ្យដើម្បីកាត់ឈ្មោះផ្ទេរកម្មសិទ្ធិឱ្យទៅឈ្មោះ [redacted] គួយអ៊ីង ។ ការលើកឡើងនេះ ក៏ស្របគ្នាទៅនឹងលិខិតបំភ្លឺចុះថ្ងៃទី១៥-០៩-២០១៤ របស់ឈ្មោះ [redacted] ប៊ុនធឿន ជាអ្នកបកប្រែ ដែលបានបញ្ជាក់ថា : ពេលដែល [redacted] អុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ុងឆោ និងឈ្មោះ [redacted] ស៊ីនធួរ បានផ្តិតមេដៃនៅចំពោះមុខសុរិយោដីនោះ គឺខ្លួនបានបកប្រែយ៉ាងច្បាស់ឱ្យចិនទាំង៨នាក់ថា ផ្តិតមេដៃលើលិខិតលក់ផ្តាច់ មិនមែនផ្តិតមេដៃលើលិខិតប្តូរប័ណ្ណជាលក្ខណៈប្រព័ន្ធទេ ហើយឈ្មោះ [redacted] ម៉ី និងឈ្មោះ [redacted] ឆឹងស្វយ ក៏បានប្រគល់ប្រាក់ឱ្យទៅចិនទាំង៨នាក់នោះរួចហើយដែរ និងស្របគ្នាទៅនឹងការបំភ្លឺចុះថ្ងៃទី១៥-០៩-២០១៤ របស់ឈ្មោះ [redacted] សាមឿន ជាអតីតអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ដែលបញ្ជាក់ថា : ការផ្តិតមេដៃរបស់ចិនទាំង៨នាក់ គឺជាការផ្តិតមេដៃលើលិខិតលក់ផ្តាច់ មិនមែនផ្តិតមេដៃដើម្បីប្តូរលក្ខណៈប្រព័ន្ធនោះទេ ។

តាមការលើកឡើងរបស់លោកមេធាវី និងការបំភ្លឺរបស់សាក្សីទាំងអស់ខាងលើ រួមទាំងរូបថត ដែលថតនៅថ្ងៃទី២១-០៤-២០០៧ ដែលជនជាប់ចោទឈ្មោះ [redacted] អុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ុងឆោ និងឈ្មោះ [redacted] ស៊ីនធួរ បានផ្តិតមេដៃនៅចំពោះមុខមន្ត្រី

សុរិយាដីនោះ ក្រុមប្រឹក្សាយល់ថា ករណីនេះ គឺជារឿងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងកិច្ចសន្យាទិញលក់ដី និងការផ្ទេរកម្មសិទ្ធិ ហើយជនជាប់ចោទទាំង៨នាក់ខាងលើនេះ ក៏បានផ្ដិតមេដៃលើលិខិតលក់ផ្ដាច់ និងបានប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ហើយ និងបានទទួលប្រាក់ពីដើមបណ្ដឹងរដ្ឋប្បវេណីដែរ តាមការអះអាងរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងការបញ្ជាក់របស់អ្នកបកប្រែឈ្មោះ [redacted] ប៊ុនធឿន ។ មិនតែប៉ុណ្ណោះឈ្មោះ [redacted] ឆុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វួយ, [redacted] យូវលោង, [redacted] ម៉ីងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ក៏បានប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិរួចហើយ ម្យ៉ាងទៀត ក្រុមប្រឹក្សាយល់ថា ការមិនព្រមមកផ្ដិតមេដៃ កាត់ឈ្មោះផ្ទេរកម្មសិទ្ធិនោះ គឺជាការមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាលក់-ទិញដី ដែលជារឿងក្ដីរដ្ឋប្បវេណីសុទ្ធសាធ ពោលគឺពុំមែនជាធាតុផ្សំនៃបទល្មើសឆបោក តាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌទេ ព្រោះជនជាប់ចោទទាំង៨នាក់ មិនបានបង្ហាញពីចេតនាទុច្ចរិត ក្នុងការបោកប្រាស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ ។ ហេតុនេះ ក្រុមប្រឹក្សាយល់ថា ពុំមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដើម្បីចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ឆុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វួយ, [redacted] យូវលោង, [redacted] ម៉ីងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ពីបទ ឆបោក តាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌទេ គប្បីក្រុមប្រឹក្សាសម្រេចឱ្យរួចផុតពីបទចោទ ។

- ចំពោះបទប្ដឹងបរិហារបង្កាច់កេរ្ដិ៍ : លោកមេធាវី [redacted] ពៅស៊ាង បានលើកឡើងថា ការចោទប្រកាន់កូនក្ដីខ្លួនពីបទប្ដឹងបរិហារបង្កាច់កេរ្ដិ៍ គឺជាការមិនត្រឹមត្រូវ ដោយហេតុថា ការដាក់ពាក្យបណ្ដឹងរបស់កូនក្ដីខ្លួនចំពោះដើមបណ្ដឹងរដ្ឋប្បវេណី [redacted] អ៊ឹងស្វួយ និង [redacted] ម៉ី ទោះបីត្រូវបានតម្កល់រឿងទុកឥតចាត់ការក្នុងរឿងព្រហ្មទណ្ឌ ប៉ុន្តែក្នុងសំអាងហេតុនេះដីកាសម្រេចតម្កល់រឿងទុកមិនចាត់ការនោះ បញ្ជាក់ច្បាស់ណាស់ថា គឺជារឿងរដ្ឋប្បវេណី ដូចនេះការប្ដឹងរបស់កូនក្ដីខ្លួនមានអង្គហេតុត្រឹមត្រូវ ដែលមិនមែនជាការប្ដឹងបរិហារបង្កាច់កេរ្ដិ៍នោះទេ ម្យ៉ាងទៀតបើគិតពីអាជ្ញាយុកាលនៃបទល្មើសប្ដឹងបរិហារបង្កាច់កេរ្ដិ៍នេះ ក៏បានហួសទៅហើយ តាមមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ។

ក្រុមប្រឹក្សាយល់ថា ការលើកឡើងរបស់លោកមេធាវីខាងលើ មានលក្ខណៈត្រឹមត្រូវត្រង់អាជ្ញាយុកាលនៃបទល្មើសបរិហារបង្កាច់កេរ្ដិ៍ ដោយហេតុថា តាមមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ចែងថា : "បទល្មើសនេះ ត្រូវផុតអាជ្ញាយុកាល ក្នុងរយៈពេល ១ឆ្នាំ គិតចាប់ពីថ្ងៃដែលបណ្ដឹងបរិហារបង្កាច់កេរ្ដិ៍បានមកដល់ ឬថ្ងៃដែលប្ដឹងបរិហារបង្កាច់កេរ្ដិ៍នេះ ដាក់មកអាជ្ញាធរមានសមត្ថកិច្ច" ហើយក្នុងរឿងក្ដីនេះ ជនជាប់ចោទជាជនជាតិចិនទាំង៨នាក់ គឺ [redacted] ឆុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វួយ, [redacted] យូវលោង, [redacted] ម៉ីងឆោ និងឈ្មោះ [redacted] ស៊ីនធួរ បានដាក់ពាក្យបណ្ដឹងពីឈ្មោះ [redacted] អ៊ឹងស្វួយ និងឈ្មោះ [redacted] ម៉ី ជាច្រើនលើកជាច្រើនសារទៅសាលាដំបូងខេត្តកំពង់ឆ្នាំង និងសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវបានតំណាងអយ្យការចេញដីកាសម្រេចតម្កល់ទុកឥតចាត់ការ ទោះបីជាបានប្ដឹងឧទ្ធរណ៍នឹងដីកានេះ ក៏ត្រូវបានអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តម្កល់ដីកាសម្រេចរបស់សាលាដំបូងដែរ ប៉ុន្តែតាមដីកាសម្រេចតម្កល់

រឿងទុកឥតចាត់ការលេខ ៦៩៥ អ.យ.ច ចុះថ្ងៃទី២២-០៩-២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលអាចបញ្ជាក់ថាជនជាប់ចោទទាំង៨នាក់ខាងលើ បានដាក់បណ្តឹងចុងក្រោយបង្អស់ទៅកាន់ឈ្មោះ [redacted] ឆឹងសួយ និងឈ្មោះ [redacted] ម៉ី ពីបទឆបោក និងរំលោភលើទំនុកចិត្ត គឺនៅថ្ងៃទី១០-០៥-២០១១ តាមរយៈលោកមេធាវី [redacted] ធាវី ដូច្នេះបើគិតមកដល់ថ្ងៃទី១៤-១១-២០១២ ជាថ្ងៃដែលពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ឆឹងសួយ និងឈ្មោះ [redacted] ម៉ី បានចូលមកដល់សាលាដំបូងរាជធានីភ្នំពេញ ប្តឹងពីជនជាប់ចោទទាំង៨នាក់ខាងលើ ពីបទ ប្តឹងបរិហារបង្កាច់កេរ្តិ៍ គឺពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានផុតអាជ្ញាយុកាលនៃបទល្មើស ប្តឹងបរិហារបង្កាច់កេរ្តិ៍រយៈពេល៦ខែមកហើយ តាមមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ហេតុនេះបណ្តឹងអាជ្ញាលើជនជាប់ចោទ [redacted] ឆុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជឹងយាន, [redacted] គួសុង, [redacted] ទើអ៊ួយ, [redacted] យូវលាង, [redacted] ម៉ឹងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ពីបទ ប្តឹងបរិហារបង្កាច់កេរ្តិ៍ ត្រូវបានរលត់ស្របតាមមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលគប្បីឲ្យរួចផុតពីបទចោទប្រកាន់នេះ ។

- ចំពោះបទប្រើប្រាស់លិខិតសាធារណៈក្លែង : ការលើកឡើងរបស់លោកមេធាវី [redacted] ពៅស៊ាង ថាការចោទប្រកាន់កូនក្តីខ្លួនពីបទល្មើសនេះ ក៏ពុំមានលក្ខណៈត្រឹមត្រូវដែរ ព្រោះអាជ្ញាយុកាលនៃបទល្មើសត្រូវបានផុតហើយ តាមមាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រោះកូនក្តីខ្លួនប្រើប្រាស់ប័ណ្ណតាំងពីឆ្នាំ១៩៩៧ ដើម្បីទិញដី ម្យ៉ាងទៀតកូនក្តីខ្លួនក៏ពុំបានដឹងថា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន ជាប័ណ្ណក្លែងដែរ ដូចនេះកូនក្តីខ្លួនពុំមានចេតនាក្នុងការប្រើប្រាស់លិខិតក្លែង ។ ក្រុមប្រឹក្សាយល់ថា ការលើកឡើងពុំមានលក្ខណៈត្រឹមត្រូវ និងមូលដ្ឋានច្បាស់លាស់អាចឲ្យក្រុមប្រឹក្សាពិចារណាបានទេ ផ្ទុយទៅវិញមានភស្តុតាងអាចបញ្ជាក់បានថា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ទាំង៨ប័ណ្ណ ចុះថ្ងៃទី១៨-០៣-១៩៩២ របស់ឈ្មោះ [redacted] ឆុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជឹងយាន, [redacted] គួសុង, [redacted] ទើអ៊ួយ, [redacted] យូវលាង, [redacted] ម៉ឹងឆោ និងឈ្មោះ [redacted] ស៊ីនធួរ គឺជាអត្តសញ្ញាណប័ណ្ណក្លែង ដូចមានក្នុងលិខិតលេខ ៤៤៨ រ.ប.ក របស់អគ្គស្នងការរង និងស្នងការនគរបាលរាជធានីភ្នំពេញ ចុះថ្ងៃទី១៣-០៦-២០១៣ (តាមសំអាងហេតុសាលក្រមព្រហ្មទណ្ឌលេខ ៧១ “ទ” ចុះថ្ងៃទី០២-១២-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ) បានបញ្ជាក់ថា ពុំមានទិន្នន័យ និងឯកសារតម្កល់ទុកនៃសាលកប័ត្រពត៌មានផ្តល់អត្តសញ្ញាណប័ណ្ណរបស់ជនទាំង៨នាក់នេះឡើយ ។ ម្យ៉ាងទៀតអត្តសញ្ញាណប័ណ្ណនេះ មានលក្ខណៈផ្ទុយនឹងលិខិតពឹងពាក់មេធា[redacted]ធាវី ត្រង់ទីកន្លែងកំណើត និងជនជាតិ ហេតុនេះអាចឲ្យក្រុមប្រឹក្សាជឿជាក់បានថា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលជនជាប់ចោទប្រើប្រាស់ដើម្បីទិញដីពីដើមបណ្តឹងរដ្ឋប្បវេណីក្នុងឆ្នាំ១៩៩៧ គឺជាអត្តសញ្ញាណប័ណ្ណក្លែង មិនតែប៉ុណ្ណោះអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្លែងនេះ ត្រូវបានបន្តប្រើប្រាស់រហូតមកដល់ពេលបច្ចុប្បន្ន ជាក់ស្តែងក្នុងឆ្នាំ២០០៧ ជនជាប់ចោទទាំង ៨នាក់បានប្រើប្រាស់អត្តសញ្ញាណប័ណ្ណក្លែងក្លាយនេះ ដើម្បីផ្តិតមេដៃលើលិខិតលក់ផ្តាច់ និងបានប្រគល់អត្តសញ្ញាណប័ណ្ណក្លែងក្លាយនេះ ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី [redacted] ឆឹងសួយ និង [redacted] ម៉ី ដើម្បីរត់ការចុះបញ្ជីដី និងកាត់ឈ្មោះផ្ទេរកម្មសិទ្ធិឲ្យទៅឈ្មោះ [redacted] គួយអ៊ីង ហើយដែលនីតិវិធីនៃការចុះបញ្ជី និងការកាត់ឈ្មោះ ផ្ទេរកម្មសិទ្ធិនេះ មិនទាន់ត្រូវបានបញ្ចប់ជាស្ថាពរទេមកដល់សព្វថ្ងៃនេះ ហេតុនេះ

សបញ្ជាក់ឲ្យឃើញថា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្លែងក្លាយ ចុះថ្ងៃទី១៣-០៩-១៩៩២ របស់ឈ្មោះ [redacted] អ៊ុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ិងឆោ និងឈ្មោះ [redacted] ស៊ីនធួរ នៅតែត្រូវបានប្រើប្រាស់រហូតមកដល់ពេលបច្ចុប្បន្ន ដោយជនជាប់ចោទទាំង៨នាក់នេះ ដែលបទល្មើសនៅតែមានអត្ថិភាព នាំឲ្យពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើឡើងត្រឹមត្រូវតាមច្បាប់ហើយ ។ ចំពោះការលើកឡើងរបស់លោកមេធាវី [redacted] ពៅស៊ាង ថាកូនក្តីខ្លួនមិនមានចេតនាប្រើប្រាស់លិខិតសាធារណៈក្លែង ព្រោះកូនក្តីខ្លួនមិនបានដឹងថាអត្តសញ្ញាណប័ណ្ណនោះក្លែងក្លាយនោះ គឺជាការដោះសារ ដែលមិនមានលក្ខណៈត្រឹមត្រូវ និងមិនមានមូលដ្ឋានអាចឲ្យក្រុមប្រឹក្សាជឿជាក់បានទេ ដោយហេតុថា បើជនជាប់ចោទមិនបានប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្លែងនោះទេ នោះនឹងមិនអាចធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនៅក្នុងឆ្នាំ១៩៩៧ និងបន្តការប្រើប្រាស់ដើម្បីលក់ដីឲ្យដើមបណ្តឹងបានទេ ។ ហេតុនេះក្រុមប្រឹក្សាយល់ថា : មានអង្គហេតុ និងភស្តុតាងគ្រប់គ្រាន់ ស៊ីសង្វាក់គ្នា ដែលបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] អ៊ុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ិងឆោ និងឈ្មោះ [redacted] ស៊ីនធួរ បានប្រើប្រាស់លិខិតសាធារណៈក្លែង (អត្តសញ្ញាណប័ណ្ណ) តាមមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ដើម្បីបានទិញលក់ដី និងធ្វើការចុះបញ្ជីដី ព្រមទាំងប្រើដើម្បីកាត់ឈ្មោះផ្ទេរកម្មសិទ្ធិដីផងដែរ ។

៤- ក្រុមប្រឹក្សាយល់ឃើញថា : ជនជាប់ចោទឈ្មោះ [redacted] អ៊ុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ិងឆោ និងឈ្មោះ [redacted] ស៊ីនធួរ បានប្រព្រឹត្តបទល្មើសប្រើប្រាស់លិខិតសាធារណៈក្លែង តាមមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ ប៉ុន្តែដោយហេតុថាបទល្មើសនេះ ជាបទល្មើសមជ្ឈិមដែលត្រូវផ្តន្ទាទោសចាប់ពី ២ឆ្នាំ ដល់៥ឆ្នាំ ហើយជនជាប់ចោទទាំង៨នាក់នេះ ពុំធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពរ ឲ្យជាប់ពន្ធនាគារពីមុនមក និងដោយហេតុថា ជនជាប់ចោទទាំង ៨នាក់នេះ មានវ័យចាស់ជរា អាយុប្រហែល៧០ ទៅ៨០ឆ្នាំហើយ (តាមការបញ្ជាក់អត្តសញ្ញាណជនជាប់ចោទ នៃសាលក្រមរបស់សាលាដំបូង) ហេតុនេះគប្បីក្រុមប្រឹក្សាពិចារណា ការអនុវត្តទោសព្យួរ លើទោសពន្ធនាគារ តាមមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

៥- ក្រុមប្រឹក្សាយល់ថា : ពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីធាតុផ្សំនៃបទល្មើស ឆបោក ចំពោះជនជាប់ចោទឈ្មោះ [redacted] អ៊ុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ិងឆោ និងឈ្មោះ [redacted] ស៊ីនធួរ តាមមាត្រា៣៧៧ និងមាត្រា៣៧៨ និងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី លើជនជាប់ចោទទាំង៨នាក់នេះ ពីបទ ប្តឹងបរិហារបង្កាច់កេរ្តិ៍ មានលក្ខណៈផ្ទុយច្បាប់ ដោយផុតអាជ្ញាយុកាល ហេតុនេះគប្បីឲ្យជនជាប់ចោទឈ្មោះ [redacted] អ៊ុងហ្វៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ិងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ត្រូវរួចផុតពីបទចោទប្រកាន់ពីបទ ឆបោក និងបទ ប្តឹងបរិហារបង្កាច់កេរ្តិ៍ ហេតុនេះគប្បីក្រុមប្រឹក្សាពិចារណាលុបចោលចំណុចបង្គាប់ឲ្យជនជាប់ចោទទាំង៨នាក់នេះ សងសំណងការខូចខាត និងសំណងជម្ងឺចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

៤៦៣

៦- ចំពោះការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង ពីបទ ប្ដឹងបរិហារបង្កាច់កេរ្តិ៍ ៖ តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង នៅដំណាក់កាលចៅក្រមស៊ើបសួរ ខ្លួនពិតជាបានដាក់ពាក្យបណ្ដឹងលើឈ្មោះ [redacted] គីងស្វាយ និងឈ្មោះ [redacted] មុី ម៉ែន នៅសាលាដំបូងខេត្តកំពង់ឆ្នាំង និងសាលាដំបូងរាជធានីភ្នំពេញ ពីបទឆបោក ម៉ែន (ឯកសារលេខ៥៣) ។ ក្រុមប្រឹក្សាយល់ថា ៖ ជនជាប់ចោទបានទទួលស្គាល់ថា បានដាក់ពាក្យបណ្ដឹងលើដើមបណ្ដឹងរដ្ឋប្បវេណីពីបទ ឆបោក និង រំលោភលើទំនុកចិត្តម៉ែន ដែលស្របគ្នាទៅនឹងពាក្យបណ្ដឹង របស់ឈ្មោះ [redacted] គួយអ៊ីង ដែលចូលដល់សាលាដំបូងខេត្តកំពង់ឆ្នាំងនៅថ្ងៃទី១៧-០២-២០១២ និងត្រូវបានអយ្យការសាលាដំបូងខេត្តកំពង់ឆ្នាំង បានសម្រេចតម្កល់រឿងទុកឥតចាត់ការតាមដីកាសម្រេចលេខ ២០០៩ អ.យ/១២ ចុះថ្ងៃទី២០-១១-២០១២ ហើយបើគិតមកដល់ថ្ងៃដែលពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចូលមកដល់សាលាដំបូងរាជធានីភ្នំពេញថ្ងៃទី១៤-១១-២០១២ ប្ដឹងឈ្មោះ [redacted] គួយអ៊ីង ពីបទ ប្ដឹងបរិហារបង្កាច់កេរ្តិ៍នោះ ឃើញថា បណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមានលក្ខណៈត្រឹមត្រូវ ម្យ៉ាងទៀត តាមដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់សាលាដំបូងខេត្តកំពង់ឆ្នាំង និងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ របស់សាលាដំបូងរាជធានីភ្នំពេញ ព្រមទាំងលិខិតចាត់ការមិនធ្វើការប្ដឹងរបស់រាជអាជ្ញានៃស្នងការរាជអាជ្ញាតុលាការតំបន់តៃប៉ិ អាចបញ្ជាក់បានថា ឈ្មោះ [redacted] គួយអ៊ីង បានប្ដឹងដើមបណ្ដឹងរដ្ឋប្បវេណីពីបទ ឆបោក ម្ដងហើយម្ដងទៀត ទោះបីមានការតម្កល់រឿងទុកឥតចាត់ការម្ដងហើយ ម្ដងទៀតក៏ដោយ ដែលអំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] គួយអ៊ីង នេះ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ហេតុនេះក្រុមប្រឹក្សាយល់ឃើញថា ការសម្រេចសេចក្តីសម្រេចរបស់សាលាដំបូង អំពីការចោទប្រកាន់ និងផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង និងសំណងជម្ងឺចិត្ត មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

៧- តំណាងមហាអយ្យការសន្និដ្ឋានថា ៖ ចំពោះការចោទប្រកាន់ពីបទ ប្ដឹងបរិហារបង្កាច់កេរ្តិ៍ និងបទប្រើប្រាស់លិខិតក្លែងមានលក្ខណៈត្រឹមត្រូវ សុំសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការ រីឯការចោទប្រកាន់ពីបទ ឆបោក សុំសភាព្រហ្មទណ្ឌ ពិនិត្យ និងពិចារណាតាមច្បាប់ ។ គប្បីក្រុមប្រឹក្សាពិចារណា ។

៨- សាលក្រមព្រហ្មទណ្ឌលេខ ៧១ "ទ" ចុះថ្ងៃទី០២-១២-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីមក មានលក្ខណៈត្រឹមត្រូវខ្លះ ខុសខ្លះ គប្បីក្រុមប្រឹក្សាតម្កល់ទុកជាបានការ នូវចំណុចដែលត្រឹមត្រូវ ហើយបដិសេធចោល នូវចំណុចដែលមិនត្រឹមត្រូវ និងកែប្រែជាថ្មីឡើងវិញតាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-០១-២០១៤ របស់លោកមេធាវី [redacted] ស៊ីណាល់ ទទួលសិទ្ធិប្ដឹងឧទ្ធរណ៍ពីជនជាប់ចោទឈ្មោះ [redacted] គួយអ៊ីង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣-០១-២០១៤ របស់លោកមេធាវី ពុធ ធាវី ទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីជនជាប់ចោទឈ្មោះ [redacted] ឆុងហ៊ៃ, [redacted] ជីនស៊ីន, [redacted] ជីងយាន, [redacted] គួសុង, [redacted] ទើអ្វយ, [redacted] យូវលាង, [redacted] ម៉ឹងឆោ និងឈ្មោះ [redacted] ស៊ីនធួរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្លះ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ : ៧១ "ទ" ចុះថ្ងៃទី០២-១២-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែ :

- ចំណុចទី១ នៃសេចក្តីសម្រេចត្រង់ : "ផ្តន្ទាទោសឈ្មោះ [redacted] ជិន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ៊ៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន ពីបទ ឆបោក និងបទ បរិហាបង្កាច់កេរ្តិ៍" *ត្រូវបដិសេធចោល* និងត្រង់ : "ផ្តន្ទាទោសឈ្មោះ [redacted] ជិនយាន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ៊ៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៥,០០០,០០០ (ប្រាំលាន) រៀល ពីបទប្រើប្រាស់លិខិតសាធារណៈក្លែង (អត្តសញ្ញាណប័ណ្ណ)" *ត្រូវកែប្រែមកជា "ផ្តន្ទាទោសឈ្មោះ [redacted] ជិនយាន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ៊ៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ២ (ពីរ)ឆ្នាំ តែទោសនេះ ត្រូវអនុវត្តទោសព្យួរធម្មតាទាំងមូល និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៥,០០០,០០០ (ប្រាំលាន) រៀល"*វិញ តាមមាត្រា៦៣០ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

- ចំណុចទី៣ នៃសេចក្តីសម្រេច ត្រូវបដិសេធចោល ។

ចំណុចក្រៅពីនេះ ត្រូវរក្សាទុកជាបានការដដែល ។

៣- ឱ្យឈ្មោះ [redacted] ជិន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ៊ៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន បានរួចផុតពីបទចោទ ពីបទ : ឆបោក និងបទ បរិហាបង្កាច់កេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១០ និងឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា៣៧៧ មាត្រា៣១១ និងមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤- បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ជិន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ៊ៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន ។

សាលដីកានេះជំនុំជម្រះ ជាសាធារណៈ ថ្ងៃទី១១-០៩-២០១៤ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ជិនយាន ឈ្មោះ [redacted] គួសុង ឈ្មោះ [redacted] ទើអ្វយ ឈ្មោះ [redacted] យូវលាង ឈ្មោះ [redacted] ម៉ឹងឆោ ឈ្មោះ [redacted] ឆុងហ៊ៃ ឈ្មោះ [redacted] ស៊ីនធួរ ឈ្មោះ [redacted] ជីនស៊ីន តែចាត់ទុកជាចំពោះមុខ, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] គួយអ៊ឹង, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆឹងស្វយ និងឈ្មោះ [redacted] ម៉ី តែចាត់ទុកជាចំពោះមុខ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨-០៩-២០១៤ ។/

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សាលដីកានេះ ស្ថាពរចំពោះជនជាប់ចោទចំនួន៨នាក់ មានឈ្មោះ [redacted] ជិន, ឈ្មោះ [redacted] គួសុង, ឈ្មោះ [redacted] ទើរឿយ, ឈ្មោះ [redacted] យូរលាង, ឈ្មោះ [redacted] ម៉ឹងឆោ, ឈ្មោះ [redacted] អ៊ុងហៀ, ឈ្មោះ [redacted] ស៊ីនធួរ, ឈ្មោះ [redacted] ជីនស៊ីន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឈ្មោះ [redacted] តែប៉ុណ្ណោះ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] , [redacted] | ហត្ថលេខា [redacted] |

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

៤៦៦